เมษายน Ransomware

27/04/2023

image: Freepik.com

DigitalHub101

អ្វីជាមេរោគ Ransomware

Ransomware ជាប្រភេទមេរោគមួយ ដែលធ្វើការចាក់សោទិន្នន័យ ដែលមាននៅក្នុងកុំព្យូទ័ររបស់ជនរងគ្រោះ ហើយទាមទារឱ្យជនរងគ្រោះផ្ញើលុយទៅឱ្យពួកគេ ជាថ្នូរនៃការបានលេខកូដយកមកដោះសោ ដើម្បីអាចបើកឯកសារទាំងនោះវិញបាន។

គ្រប់គ្នាសុទ្ធតែជាគោលដៅនៃការវាយប្រហាររបស់មេរោគ Ransomwareនេះ មិនថាពួកគេជាបុគ្គលឯកជន អង្គការមិនស្វែងរកប្រាក់ចំណេញ ក្រុមហ៊ុន ឬស្ថាប័នរដ្ឋនោះទេ។

DigitalHub101

វិធីសាស្ត្រដែល Ramsomware គំរាមជនរងគ្រោះ

ប្រសិនបើជនរងគ្រោះបដិសេធមិនព្រមផ្ញើលុយ នោះឧក្រិដ្ឋជនអាចគំរាមថាពួកគេនឹងបំផ្លាញទិន្នន័យឬធ្វើឱ្យបែកធ្លាយទិន្នន័យលើអ៊ីនធឺណិត ឬលក់ទិន្នន័យនោះទៅឱ្យក្រុមណាមួយជាដើម។

ទោះជាយ៉ាងណាក៏ដោយ ការព្រមផ្ញើលុយទៅឱ្យក្រុមឧក្រិដ្ឋជន ក៏មិនអាចធានាថានឹងអាចបើកឯកសារ ឬទិន្នន័យទាំងនោះវិញដែរ លើសពីនេះ អាចធ្វើឱ្យក្រុមឧក្រិដ្ឋជន បន្តវាយប្រហារលើជនរងគ្រោះបន្ថែមទៀត ដើម្បីជំរិតទារប្រាក់ឱ្យបានកាន់តែច្រើន។

DigitalHub101

មូលហេតុ
នៃការឆ្លង Ransomware

មិនខុសពីមេរោគផ្សេងៗដែរ មេរោគ Ransomware អាចឆ្លងចូលក្នុងកុំព្យូទ័ររបស់ជនរងគ្រោះតាមមធ្យោបាយជាច្រើន ដូចជាតាមរយៈការប្រើ កម្មវិធីដែលមិនមានអាជ្ញាប័ណ្ណ ការប្រើUSB រួមគ្នា ការចុចលើតំណភ្ជាប់ Phishing, និងតាមរយៈការចូលទៅកាន់គេហទំព័រដែលមានរោគជាដើម។ល។

DigitalHub101

វិធីសាស្ត្រការពារ

ដើម្បីការពារកុំឱ្យអ្នកក្លាយជាជនរងគ្រោះពីមេរោគ Ransomware អ្នកគួរធ្វើការបម្រុងទុកឯកសារ ឬទិន្នន័យឱ្យបានជាប្រចាំ ធ្វើបច្ចុប្បន្នភាពកម្មវិធី(Software)ឱ្យបានញឹកញាប់ កុំប្រើកម្មវិធីដែលមិនមានអាជ្ញាប័ណ្ណ ប្រុងប្រយ័ត្នមុននឹងចុចលើតំណភ្ជាប់ ឬទាញយកកម្មវិធីណាមួយដែលមិនស្គាល់ប្រភព និងបន្តស្វែងយល់ពីការការពារសុវត្ថិភាព នៅលើ អ៊ីនធឺណិត។

DigitalHub101